ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងរដ្ឋប្បវេណីលេខ ៨៩៨

ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២

សាលក្រមលេខ ០២០ (ទ)

ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៣

តាងនាមប្រជារាស្ត្រខ្មែរ

**សាលាដំបូងខេត្តកណ្ដាល**

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់

នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣

ដោយមានសមាសភាព:

-លោក [redacted] ចៅក្រម

-លោក [redacted] ក្រឡាបញ្ជី

-ដើមចោទឈ្មោះ [redacted]គីមលៀង ភេទស្រី កើតថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៥០ ជនជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ [redacted] ។

មានលោក [redacted]ជាមេធាវីតំណាងដោយអាណត្តិ ។

-ចុងចម្លើយឈ្មោះ [redacted]សុង ហៅ សេង ភេទស្រី ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន[redacted] ។

មេធាវីតំណាងដោយអាណត្តិ គ្មាន ។

## **អង្គហេតុ និងចំណុចវិវាទ**

**១.ខ្លឹមសារនៃសាលក្រមដែលទាមទារដោយដើមចោទ:**

១.១.បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted]សុង ហៅ សេង សងប្រាក់ដើមចំនួន ១៣.០០០ (មួយម៉ឺនបីពាន់) ដុល្លារអាមេរិក មកឱ្យដើមចោទឈ្មោះ[redacted]គីមលៀង ។

១.២.បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted]សុង ហៅ សេង បង់ការប្រាក់ចំនួន ៧២០ (ប្រាំពីររយម្ភៃ) ដុល្លារអាមេរិក ក្នុង១ខែ មកឱ្យដើមចោទ គិតចាប់ពីខែឧសភា ឆ្នាំ២០២២ រហូតដល់ថ្ងៃអនុវត្តចប់សព្វគ្រប់ ។

១.៣.បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted]សុង ហៅ សេង បង់ប្រាក់ពិន័យចំពោះការបង់ការប្រាក់យឺតយ៉ាវចំនួន ៥ (ប្រាំភាគរយ) ក្នុង១ឆ្នាំ នៃប្រាក់ដើមចំនួន ១៣.០០០ (មួយម៉ឺនបីពាន់) ដុល្លារអាមេរិក មកឱ្យដើមចោទឈ្មោះ [redacted] គីមលៀង គិតចាប់ពីខែឧសភា ឆ្នាំ២០២២ រហូតដល់ថ្ងៃអនុវត្តចប់សព្វគ្រប់ ។

១.៤.បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted]សុង ហៅ សេង សងថ្លៃខូចខាត និងជំងឺចិត្ត ការខាតបង់ពេលវេលា និងសេវាកម្មច្បាប់សរុបចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក មកឱ្យដើមចោទឈ្មោះ[redacted]គីមលៀង ។

១.៥.ស្នើសុំអនុវត្តបណ្ដោះអាសន្នត្រង់ការទាមទារចំណុច១ ។



Scanned with CamScanner

២.ការពន្យល់ត្រួសៗអំពីរឿងក្ដី:

កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០ ចុងចម្លើយឈ្មោះ [redacted] សុង ហៅ សេង បានខ្ចីប្រាក់ពីដើមចោទឈ្មោះ [redacted] គីមលៀង ចំនួន ៤.០០០ (បួនពាន់) ដុល្លារអាមេរិក ដោយយល់ព្រមបង់ការប្រាក់ចំនួន ២២០ (ពីររយម្ភៃ) ដុល្លារអាមេរិក ក្នុង១ខែ ដូចមានបញ្ជាក់នៅក្នុងឯកសារភស្តុតាងទី១ ។ បន្ទាប់មកនៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២០ ចុងចម្លើយបានខ្ចីប្រាក់ពីដើមចោទជាលើកទី២ ចំនួន ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក បន្ថែមទៀត ដោយយល់ព្រមបង់ការប្រាក់ចំនួន ៣០០ (បីរយ) ដុល្លារអាមេរិក ក្នុង១ខែ ដូចមានបញ្ជាក់នៅក្នុងឯកសារភស្តុតាងទី២ ។ ក្រោយមកចុងចម្លើយបានខ្ចីប្រាក់ពីដើមចោទជាបន្តបន្ទាប់សម្រាប់យកទៅប្រើប្រាស់ក្នុងគោលបំណងជាច្រើនដូចជា សម្រាប់ការកូន សម្រាប់ទិញម៉ូតូ សម្រាប់ធ្វើធ្មេញ និងសម្រាប់យកទៅប្រើប្រាស់ក្នុងពេលបុណ្យភ្ជុំបិណ្ឌ សរុបចំនួន ៤.០០០ (បួនពាន់) ដុល្លារអាមេរិក បន្ថែមទៀត ដោយសន្យាបង់ការប្រាក់ចំនួន ២០០ (ពីររយ) ដុល្លារអាមេរិក ក្នុង១ខែ ការខ្ចីចុងក្រោយនេះ គឺមិនបានធ្វើកិច្ចសន្យា តែចុងចម្លើយបានទទួលស្គាល់នៅក្នុងកំណត់ហេតុប្រជុំដោះស្រាយវិវាទអំពីការខ្ចីប្រាក់នៅសាលាឃុំស្លាងភ្នំ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២២ ដូចមានបញ្ជាក់នៅក្នុងឯកសារភស្តុតាងទី៣ ។ ដោយសារតែភាគីចុងចម្លើយមិនបានសងប្រាក់ដើម និងការប្រាក់មកឱ្យដើមចោទ ទើបដើមចោទដាក់ពាក្យបណ្ដឹងមកតុលាការតែម្ដង ។

៣.ការអះអាងរបស់ភាគី:

-មេធាវី [redacted] បានអះអាងថា ៖ ខ្ញុំបាទសូមរក្សាខ្លឹមសារនៃការទាមទារ និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់អំពីការទាមទារ និងមូលហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារដែលមាននៅក្នុងពាក្យបណ្ដឹងរបស់ខ្ញុំបាទចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២ ទុកជាបានការដដែល ។ នៅក្នុងការប្ដឹងទាមទារប្រាក់ដើមចំនួន ១៣.០០០ (មួយម៉ឺនបីពាន់) ដុល្លារអាមេរិចនេះ គឺកូនក្ដីខ្ញុំបាទមានភស្តុតាង ដែលបញ្ជាក់អំពីការខ្ចីប្រាក់ត្រឹមត្រូវ ដូចជា កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០២០ ដែលចុងចម្លើយបានខ្ចីប្រាក់ចំនួន ៥.០០០ (ប្រាំពាន់) ដុល្លារអារិក និងមានស្នាមមេដៃរបស់ចុងចម្លើយនៅលើលិខិតខ្ចីប្រាក់នេះជាភស្តុតាងស្រាប់ ដោយការខ្ចីប្រាក់លើកទី១នេះ គូភាគីបានឯកភាពគ្នាទៅលើការប្រាក់ចំនួន ៣០០ (បីរយ) ដុល្លារអាមេរិក ក្នុង១ខែ ។ ភស្តុតាងទី២ គឺលិខិតខ្ចីប្រាក់ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០ ដែលចុងចម្លើយបានខ្ចីប្រាក់ពីកូនក្ដីខ្ញុំចំនួន ៤.០០០ (បួនពាន់) ដុល្លារអាមេរិក និងបានឯកភាពបង់ការប្រាក់ចំនួន ២២០ (ពីររយម្ភៃ) ដុល្លារអាមេរិក ក្នុង១ខែ ហើយក៏មានស្នាមមេដៃរបស់កូនបំណុលនៅលើលិខិតខ្ចីប្រាក់នេះផងដែរ ។ ក្រោយមកទៀតចុងចម្លើយ បានខ្ចីប្រាក់ពីកូនក្ដីខ្ញុំជាបន្តបន្ទាប់សរុបចំនួន ៤.០០០ (បួនពាន់) ដុល្លារអាមេរិក ដោយភាគីបានឯកភាពគ្នាបង់ការប្រាក់ចំនួន ២០០ (ពីររយ) ដុល្លារអាមេរិក ក្នុង១ខែ ។ ចំពោះការខ្ចីប្រាក់លើកទី៣នេះ គឺចុងចម្លើយបានស្នើសុំយកទៅប្រើប្រាស់ក្នុងគោលបំណងមួយចំនួន ដូចជាយកទៅការកូន, សម្រាប់យកទៅទិញរ៉ឺម៉ក់, សម្រាប់យកទៅធ្វើធ្មេញ និងខ្ចីប្រាក់សម្រាប់យកទៅប្រើប្រាស់ក្នុងពិធីបុណ្យភ្ជុំបិណ្ឌ ។ ចំពោះការខ្ចីប្រាក់លើកទី៣នេះ ថ្វីត្បិតតែមិនបានធ្វើលិខិតខ្ចីប្រាក់ ក៏ប៉ុន្តែភាគីចុងចម្លើយបានទទួលថាខ្លួនពិតជាបានខ្ចីប្រាក់សរុបពីកូនក្ដីខ្ញុំចំនួន ១៣.០០០ (មួយម៉ឺនបីពាន់) ដុល្លារអាមេរិក ពិតប្រាកដមែន ភស្តុតាងដែលបញ្ជាក់លើការខ្ចីប្រាក់លើកទី៣នេះ គឺមានបញ្ជាក់នៅក្នុងកំណត់ហេតុដោះស្រាយវិវាទនៅសាលាឃុំស្លាងភ្នំ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២ ដែលមានស្នាមមេដៃភាគីចុងចម្លើយ និងភស្តុតាងមួយទៀតនោះ គឺកំណត់ហេតុដោះស្រាយវិវាទនៅសាលាឃុំស្លាងភ្នំចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២២ ដែលចុងចម្លើយបានទទួលស្គាល់ថា ខ្លួនពិតធ្លាប់បានខ្ចីប្រាក់ពីដើមចោទចំនួន ១៣.០០០ (មួយម៉ឺនបីពាន់) ដុល្លារអាមេរិកពិតប្រាកដមែន ។ ទោះបីជាកន្លងមកភាគីចុងចម្លើយធ្លាប់បាននិយាយដោយ



Scanned with CamScanner

ផ្ទាល់មាត់ថាខ្លួនបានសងប្រាក់ទៅឱ្យដើមចោទវិញរួចហើយ តែចុងចម្លើយមិនមានភស្តុតាងណាមួយបញ្ជាក់អំពីការអះអាងថាបានសងប្រាក់នោះទេ ។ ការនិយាយអះអាងរបស់ចុងចម្លើយនោះ គឺគ្រាន់តែជាលេសដើម្បីរួចផុតកាតព្វកិច្ចនៃការសងប្រាក់តែប៉ុណ្ណោះ ។ ហេតុដូច្នេះ ខ្ញុំសូមឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារក្នុងពាក្យបណ្តឹងរបស់ខ្ញុំបាទ ដើម្បីផ្តល់នូវយុត្តិធម៌ទៅឱ្យភាគីដើមចោទដែលបានឱ្យប្រាក់ទៅភាគីចុងចម្លើយខ្ចីហើយមិន ព្រមសងប្រាក់នេះមកវិញ ។

-ដើមចោទឈ្មោះ [redacted] គឹមលៀង បានអះអាងថា ៖ នាងខ្ញុំមិនដែលបានទទួលការសងប្រាក់ពីភាគីចុងចម្លើយម្តងណានោះទេ ហើយក៏មិនដែលបានទទួលសូម្បី ១ (មួយ) ដុល្លារអាមេរិក ។ ប្រសិនបើនាងខ្ញុំបានទទួលការសងនោះ ម្ល៉េះនាងខ្ញុំមិនទៅទារប្រាក់ពីចុងចម្លើយដល់ផ្ទះចំនួន ៣ (បី) ដងនោះទេ មុនពេលនាងខ្ញុំសម្រេចដាក់ពាក្យបណ្តឹងទៅសាលាឃុំស្ពានថ្ម ។ នៅពេលដែលទៅជួបចុងចម្លើយនៅផ្ទះនោះ គឺមានរូបនាងខ្ញុំ ប្តីនាងខ្ញុំ ផ្អូនរបស់ខ្ញុំ និងកូនរបស់ខ្ញុំ បានទៅជួបចុងចម្លើយ និងប្តីរបស់គាត់ដល់ផ្ទះ ។ ចុងចម្លើយមិនត្រឹមតែមិនព្រមសងប្រាក់នាងខ្ញុំ គាត់ក៏បានបែរគូថ និងទះកំប៉េះគូថដាក់នាងខ្ញុំ និងបាននិយាយថាប្តឹងដល់ណាប្តឹងទៅ ។ ចំពោះទង្វើ និងសម្តីដែលចុងចម្លើយបាននិយាយ និងបានធ្វើមកលើនាងខ្ញុំ បានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កិត្តិយសនាងខ្ញុំនៅចំពោះមុខផ្អូន និងកូនរបស់ខ្ញុំ ។

-ចុងចម្លើយ [redacted] សុង ហៅ សេង បានអះអាងថា៖ នាងខ្ញុំទទួលស្គាល់ថាពិតជាបានខ្ចីប្រាក់ពី ភាគីដើមចោទបន្តបន្ទាប់សរុបចំនួន ១៣.០០០ (មួយម៉ឺនបីពាន់) ដុល្លារអាមេរិក ដោយព្រមព្រៀងបង់ការប្រាក់ចំនួន ៧២០ (ប្រាំពីររយម្ភៃ) ដុល្លារអាមេរិកក្នុង១ខែ ដោយបង់ការប្រាក់នេះ២ដងក្នុង១ខែ បង់ដើមខែចុងខែ ។ ហើយប្រហែលជានៅក្នុងអំឡុងខែឧសភា ឆ្នាំ២០២២ នាងខ្ញុំបានខ្ចីប្រាក់ពីធនាគារហត្ថាកសិករចំនួន ១៥.០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាកិក ខ្ញុំក៏បានយកទៅសងម្ចាស់បំណុលឈ្មោះ [redacted] គឹមលៀង ចំនួន ១៣.០០០ (មួយម៉ឺនបីពាន់) ដុល្លារអាមេរិក ។ ការសងប្រាក់ចំនួន ១៣.០០០ (មួយម៉ឺនបីពាន់) ដុល្លារអាមេរិក ទៅឱ្យដើមចោទនេះ គឺខ្ញុំបានហុចឱ្យគាត់ដោយផ្ទាល់ដៃ មិនមានធ្វើលិខិតស្នាមអ្វីនោះទេ ព្រោះកាលខ្ចីប្រាក់ក៏ហុចទៅវិញទៅមកដូចនេះដែរ ។

**៤.ចំណុចវិវាទ៖** ដើមចោទទាមទារប្រាក់ពីចុងចម្លើយចំនួន ១៣.០០០ (មួយម៉ឺនបីពាន់) ដុល្លារអាមេរិក តែចុងចម្លើយអះអាងថាបានសងគ្រប់ចំនួនរួចហើយ ។

**៥.ចំណុចគ្មានវិវាទ៖** ដើមចោទទាមទារប្រាក់ពីចុងចម្លើយចំនួន ១៣.០០០ (មួយម៉ឺនបីពាន់) ដុល្លារអាមេរិក ហើយចុងចម្លើយក៏បានទទួលស្គាល់ថាបានខ្ចីប្រាក់ពីដើមចោទចំនួន ១៣.០០០ (មួយម៉ឺនបីពាន់) ដុល្លារអាមេរិក ប្រាកដមែន ។

**៦.ភស្តុតាង៖**

**៦.១.ភស្តុតាងភាគីដើមចោទ**

-លិខិតខ្ចីប្រាក់ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០២០ ។

-លិខិតខ្ចីប្រាក់ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០ ។

-ពាក្យបណ្តឹង ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២ (ប្តឹងទៅសាលាឃុំស្ពានថ្ម) ។

-កំណត់ហេតុចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២ របស់សាលាឃុំស្ពានថ្ម ។

-លិខិតអញ្ជើញចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២២ របស់មេធាវី [redacted] ។

-កំណត់ហេតុចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២២ សាលាឃុំស្ពានថ្ម ។

**៦.២.ភស្តុតាងភាគីចុងចម្លើយ**



Scanned with CamScanner

-តារាងកាលវិភាគសងប្រាក់ (វគ្គកម្ចីលើកទី២) ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២ របស់ធនាគារហត្ថាកសិករ ម.ក ។

-កំណត់ហេតុដោះស្រាយវិវាទ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២២ ។

## សំអាងហេតុ

១.ឃើញថាតាមពាក្យបណ្តឹងចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២ របស់មេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិដើមចោទឈ្មោះ [redacted] គីមលៀង គឺជាសមត្ថកិច្ចរបស់សាលាដំបូងខេត្តកណ្តាល យោងតាមមាត្រា ៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

២.ដើមចោទបានប្តឹងទាមទារឲ្យចុងចម្លើយសងប្រាក់ដើមចំនួន ១៣.០០០ (មួយម៉ឺនបីពាន់) ដុល្លារអាមេរិក ដោយអះអាងថាកាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០ ចុងចម្លើយបានខ្ចីប្រាក់ពីដើមចោទចំនួន ៤.០០០ (បួនពាន់) ដុល្លារអាមេរិក ដោយយល់ព្រមបង់ការប្រាក់ប្រាក់ចំនួន ២២០ (ពីររយម្ភៃ) ដុល្លារអាមេរិក ក្នុង១ខែឲ្យដើមចោទ ដោយមានឯកសារបញ្ជាក់ផងដែរ ។ បន្ទាប់មកនៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២០ ចុង ចម្លើយបានខ្ចីប្រាក់ពីដើមចោទចំនួន ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក បន្ថែមទៀត ដោយយល់ព្រមបង់ការប្រាក់ចំនួន ៣០០ (បីរយ) ដុល្លារអាមេរិក ក្នុង១ខែឲ្យដើមចោទ ដោយមានឯកសារបញ្ជាក់ផងដែរ ។ បន្ទាប់មកទៀត ចុងចម្លើយបានខ្ចីប្រាក់ពីដើមចោទជាបន្តបន្ទាប់ទៀត សម្រាប់យកទៅប្រើប្រាស់សម្រាប់ការកូន សម្រាប់ទិញរ៉ឺម៉ក សម្រាប់ធ្វើធ្មេញ និងសម្រាប់យកទៅប្រើប្រាស់ក្នុងពេលបុណ្យភ្ជុំបិណ្ឌ សរុបចំនួន ៤.០០០ (បួនពាន់) ដុល្លារអាមេរិក ដោយសន្យាបង់ការប្រាក់ចំនួន ២០០ (ពីររយ) ដុល្លារអាមេរិក ក្នុង១ខែឲ្យដើមចោទ ។ ចំពោះការខ្ចីលើកទី៣នេះ មិនមានឯកសារបញ្ជាក់ទេ តែភាគីចុងចម្លើយបានទទួលស្គាល់នៅពេលដោះស្រាយវិវាទនៅសាលាឃុំស្ពានថ្ម កាលពីថ្ងៃ១៧ ខែតុលា ឆ្នាំ២០២២ ។ ចាប់តាំងពីខែឧសភា ឆ្នាំ២០២២ មក ចុងចម្លើយមិនបានសងប្រាក់ដើមមកឲ្យដើមចោទនោះទេ ហើយការប្រាក់ក៏លែងបង់ឲ្យដើមចោទផងដែរ ។ ចំណែកចុងចម្លើយបានអះអាងថាខ្លួនទទួលស្គាល់ពិតជាបានខ្ចីប្រាក់ពីដើមចោទសរុបចំនួន ១៣.០០០ (មួយម៉ឺនបីពាន់) ដុល្លារអាមេរិក ប្រាកដមែន តែបានខ្ចីប្រាក់ពីធនាគារហត្ថាកសិករសងដើមចោទរួចហើយ តែការសងនោះគឺមិនបានធ្វើលិខិតស្នាមទេ ព្រោះពេលខ្ចីក៏មិនបានធ្វើលិខិតស្នាមដែរ ។ ឃើញថា ការទាមទាររបស់ដើមចោទមានភស្តុតាង (លិខិតខ្ចីប្រាក់) និងចុងចម្លើយទទួលស្គាល់ថាពិតជាបានខ្ចីប្រាក់ពីដើមចោទពិតមែន ។ ដូច្នេះតុលាការគប្បីពិចារណាចំពោះការទាមទារប្រាក់ដើមរបស់ដើមចោទតាមមាត្រា ៥៧៨ នៃក្រមរដ្ឋប្បវេណី ។

៣.ដើមចោទទាមទារបន្ថែមបង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] សុង ហៅ សេង បង់ការប្រាក់ចំនួន ៧២០ (ប្រាំពីររយម្ភៃ) ដុល្លារអាមេរិក ក្នុង១ខែ មកឲ្យដើមចោទ គិតចាប់ពីខែឧសភា ឆ្នាំ២០២២ រហូតដល់ថ្ងៃអនុវត្តចប់សព្វគ្រប់ ។ ឃើញថា តាមភស្តុតាង (លិខិតខ្ចីប្រាក់) និងការទទួលស្គាល់របស់ចុងចម្លើយ គឺចុងចម្លើយយល់ព្រមបង់ការប្រាក់ចំនួន ៧២០ (ប្រាំពីររយម្ភៃ) ដុល្លារអាមេរិក ក្នុង១ខែ មកឲ្យដើមចោទ ។ ដូច្នេះតុលាការគប្បីពិចារណាតាមការទាមទាររបស់ដើមចោទ តាមមាត្រា ៥៨៣, ៥៨៤ និង ៣៩៩ នៃក្រមរដ្ឋប្បវេណី ។

៤.ដើមចោទទាមទារបង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] សុង ហៅ សេង បង់ប្រាក់ពិន័យចំពោះការបង់ការប្រាក់យឺតយ៉ាវចំនួន ៥ (ប្រាំភាគរយ) ក្នុង១ឆ្នាំ នៃប្រាក់ដើមចំនួន ១៣.០០០ (មួយម៉ឺនបីពាន់) ដុល្លារអាមេរិក មកឲ្យដើមចោទឈ្មោះ [redacted] គីមលៀង គិតចាប់ពីខែឧសភា ឆ្នាំ២០២២ រហូតដល់ថ្ងៃអនុវត្តចប់សព្វគ្រប់ ។ ឃើញថា ការទាមទារចំណុចនេះមិនមានភស្តុតាងគ្រប់គ្រាន់ដែលអាចឲ្យតុលាការលើកមកពិចារណាបាននោះទេ ។

៥.ដើមចោទទាមទារបង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] សុង ហៅ សេង សងថ្លៃខូចខាត និងជំងឺចិត្ត ការខាតបង់ពេល



Scanned with CamScanner

វេលា និងសេវាកម្ម ច្បាប់សរុបចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក មកឱ្យដើមចោទឈ្មោះ [redacted] គីមលៀង ។ ដោយអះអាងថាចុងចម្លើយបានគេចវេសមិនបំពេញកាតព្វកិច្ចសងប្រាក់មកឱ្យដើមចោទវិញ ធ្វើឱ្យដើមចោទខាតបង់ពេលវេលា ជំងឺចិត្ត សេវាកម្មច្បាប់ និងបន្ទុកចំណាយក្នុងនីតិវិធីតុលាការ ។ ឃើញថា ការទាមទារនេះអាចឱ្យតុលាការលើកមកពិចារណាបាន តាមមាត្រា ៣៩៨ នៃក្រមរដ្ឋប្បវេណី ។

៦.ដើមចោទទាមទារស្នើសុំអនុវត្តបណ្ដោះអាសន្នត្រង់ការទាមទារចំណុច១ នៃការទាមទារ ។ ឃើញថា ចុងចម្លើយបានទទួលស្គាល់ខ្លួនពិតជាបានខ្ចីប្រាក់ពីដើមចោទសរុបចំនួន ១៣.០០០ (មួយម៉ឺនបីពាន់) ដុល្លារអាមេរិក ពិតមែន តែបានអះអាងថាបានសងរួចហើយ តែមិនមានភស្តុតាងបញ្ជាក់អំពីការសងនេះទេ ។ ដូច្នេះតុលាការគប្បីពិចារណាតាមការទាមទារ ។

៧.ចំពោះប្រាក់ប្រដាប់ក្ដី តុលាការគប្បីពិចារណាតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**សេចក្ដីសម្រេចបញ្ចប់**

១.ឱ្យចុងចម្លើយឈ្មោះ [redacted] សុង ហៅ សេង ភេទស្រី ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន [redacted] *សងប្រាក់ដើមចំនួន ១៣.០០០ (មួយម៉ឺនបីពាន់) ដុល្លារអាមេរិក* ឱ្យទៅដើមចោទឈ្មោះ [redacted] គីមលៀង ភេទស្រី កើតថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៥០ ជនជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ ៣៦ ផ្លូវលំ០០៥ ភូមិទួលរកា១ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

២.ឱ្យចុងចម្លើយបង់ការប្រាក់ចំនួន ៧២០ (ប្រាំពីររយម្ភៃ) ដុល្លារអាមេរិក ក្នុងមួយខែ នៃប្រាក់ដើមចំនួន ១៣.០០០ (មួយម៉ឺនបីពាន់) ដុល្លារអាមេរិក គិតចាប់ពីខែឧសភា ឆ្នាំ២០២២ រហូតដល់ថ្ងៃសងប្រាក់ដើមគ្រប់ចំនួនឱ្យទៅដើមចោទ ។

៣.បង្គាប់ឱ្យចុងចម្លើយសងថ្លៃខូចខាត និងជំងឺចិត្ត ការខាតបង់ពេលវេលា និងសេវាកម្មផ្នែកច្បាប់សរុបចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល ឱ្យទៅដើមចោទ ។

៤.សាលក្រមនេះអាចអនុវត្តបណ្ដោះអាសន្នត្រង់ចំណុចទី១ នៃសេចក្ដីសម្រេច ។

៥.ច្រានចោលការទាមទារបង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ពិន័យចំពោះការបង់ប្រាក់យឺតយ៉ាវចំនួន ៥ (ប្រាំ) ភាគរយ ក្នុង១ឆ្នាំនៃប្រាក់ដើមចំនួន ១៣.០០០ (មួយម៉ឺនបីពាន់) ដុល្លារអាមេរិក រហូតដល់ថ្ងៃសងប្រាក់ដើមគ្រប់ចំនួនឱ្យទៅដើមចោទ ។

៦.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ ។

សាលក្រមនេះប្រកាសជាសាធារណៈ នៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៣ ចំពោះមុខដើមចោទ និងចុងចម្លើយ បើកសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ៦រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ធ្វើនៅខេត្តកណ្ដាល.ថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រម**

[redacted]



Scanned with CamScanner